## ៣. ក្របខ័ណ្ឌយុទ្ធសាស្ត្រនិងអាទិភាព : ២០០៤-០៨

### ៣.១. ទិសដៅយុទ្ធសាស្ត្ររួម

### ៣.១.១. ការពង្រីកនិងពង្រីកយុទ្ធសាស្ត្រ ២០០៤-០៨

នៅដំណាក់ទី ១ នៃការអនុវត្ត ESP ២០០១-០៥ បានផ្តោតការយកចិត្តទុកដាក់ទៅលើការកាត់បន្ថយចំណាយដែលជាឧបសគ្គ នៃការចូលរៀននៅកំរិតអប់រំមូលដ្ឋាន។ យុទ្ធសាស្ត្រជាអាទិភាពរបស់ ESP ២០០៤-០៨ គឺការកាត់បន្ថយចំណាយជាបន្ត០ទៀត តាមរយៈការលុបបំបាត់វិភាគទានក្រៅផ្លូវការរបស់មាតាបិតាសិស្សចាប់ពីថ្នាក់ទី១-៩ និងការកាត់បន្ថយសិស្សត្រួតថ្នាក់ និងបោះបង់ការសិក្សា ដែលជាបន្ទុកចំណាយបន្ថែមរបស់ឪពុកម្តាយសិស្ស។ យុទ្ធសាស្ត្រមួយទៀត គឺដាក់អោយអនុវត្តកំណែទំរង់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តជាប្រព័ន្ធផ្អែកលើការបំពេញការងារ។ យុទ្ធសាស្ត្រទាំងនោះត្រូវបានបំពេញបន្ថែម ដោយការពង្រីកកម្មវិធីអភិវឌ្ឍន៍សំភាររូបវ័ន្តនៅក្នុងតំបន់ដែលបច្ចុប្បន្នពុំទាន់បានផ្តល់គ្រប់គ្រាន់។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០១-០៥ ផ្តោតការយកចិត្តទុកដាក់ទៅលើ ការពង្រីកកាលានុវត្តភាពទទួលការអប់រំក្រោយមធ្យមសិក្សាតាមរយៈការពង្រឹងភាពជាដៃគូរវាងសាធារណៈ ឯកជន។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៤-០៨ បានផ្តល់អាទិភាពខ្ពស់ចំពោះការជំរុញអោយមានអន្តរាគមន៍ផ្អែកលើតំរូវការ តាមរយៈលើកទឹកចិត្តបន្ថែមទៀតដល់ការចូលរួមរបស់ផ្នែកឯកជន និងសហគមន៍ ចំពោះការអប់រំមធ្យមសិក្សាទុតិយភូមិ ការបណ្តុះបណ្តាលជំនាញ ឧត្តមសិក្សា និងការអភិវឌ្ឍនិងគាំពារកុមារតូច។ មុខសញ្ញាសំរាប់អន្តរាគមន៍ទាំងនេះ គឺយុវជនគ្មានការងារធ្វើ និងយុវជនគ្មានជំនាញ ដែលអ្នកទាំងនោះគឺជាកំលាំងចលករនៅក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់កម្ពុជា។

អាទិភាពយុទ្ធសាស្ត្រសំខាន់ *សំរាប់ធានាការចូលរៀនប្រកបដោយសមធម៌នៅកំរិតអប់រំមូលដ្ឋាន* នឹងត្រូវកាត់បន្ថយបានយ៉ាងច្រើននូវការចំណាយក្រៅផ្លូវការរបស់មាតាបិតាសិស្ស ការចំណាយផ្ទាល់និងប្រយោលដែលពាក់ព័ន្ធដល់អត្រាត្រួតថ្នាក់ និងបោះបង់ការសិក្សាខ្ពស់ ដែលបញ្ហានេះធ្វើអោយប៉ះពាល់យ៉ាងខ្លាំងដល់សិស្សក្រីក្របំផុត។ មានយុទ្ធសាស្ត្របន្ទាប់បន្សំមួយ គឺការបង្កើនថវិកាដំណើរការសាលារៀនអោយបានគ្រប់គ្រាន់ ដើម្បីជំនួសអោយវិភាគទានក្រៅផ្លូវការរបស់មាតាបិតាសិស្ស និងបង្កើនការគ្រប់គ្រងថែមទៀតនៅថ្នាក់សាលារៀន និងសហគមន៍ ។ ការសាងសង់សាលារៀននៅជិតផ្ទះសិស្ស នឹងកាត់បន្ថយបានការចំណាយផ្ទាល់ និងចំណាយឱកាសសំរាប់គ្រួសារសិស្ស ។ ការពង្រីកកម្មវិធីចូលរៀនឡើងវិញ សំរាប់សិស្សបោះបង់ការសិក្សា និងក្រុមងាយទទួលរងគ្រោះ គឺជាសមាសភាគមួយនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ។ យុទ្ធសាស្ត្រមួយផ្សេងទៀត គឺការចាត់

វិធានការកែលំអប្រសិទ្ធភាពនៃការពង្រាយបុគ្គលិក និងការប្រើប្រាស់សំភាររូបវ័ន្តអប់រំ ដើម្បីធ្វើអោយការប្រើប្រាស់ធនធានបានប្រសើរឡើង ។

យុទ្ធសាស្ត្រទាំងនេះ នឹងត្រូវការធនធានបន្ថែមទៀតពីរាជរដ្ឋាភិបាល ។ ដូចនេះ អាទិភាពមួយដែលត្រូវបង្កើននៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៤-០៨ *គឺការពង្រីកឱកាសអប់រំក្រោយកំរិតអប់រំមូលដ្ឋាន* តាមរយៈ វិធានការដែលអាចបង្កើនការចូលរួមរបស់មាតាបិតាសិស្ស សហគមន៍ សហគ្រាសឯកជន ក្រុមហ៊ុនតូចៗ និងគ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលឯកជនក្នុងការផ្តល់សេវាកម្មអប់រំ ។ យុទ្ធសាស្ត្រសំខាន់មួយអាចជាការកែទំរង់ស្ថាប័ន និងហិរញ្ញវត្ថុ ដែលនាំអោយមានស្វ័យភាពថវិកាដំណើរការដ៏ធំ និងសិទ្ធិអំណាចក្នុងការរកប្រាក់ចំណូល សំរាប់មជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងគ្រឹះស្ថានឧត្តមសិក្សា។ សំណើយុទ្ធសាស្ត្រកំណែទំរង់ស្ថាប័ន រួមបញ្ចូលនូវសិទ្ធអំណាចដ៏ច្រើនសំរាប់គណៈកម្មការជាតិបណ្តុះបណ្តាល ការបង្កើតបណ្តាញមជ្ឈមណ្ឌលសិក្សាសហគមន៍ និងបែបបទផ្តល់ហិរញ្ញប្បទានរបស់អ្នកប្រើប្រាស់ផ្សេងៗគ្នា និងមានភាពទន់ភ្លន់។ យុទ្ធសាស្ត្រទាំងនេះ នឹងត្រូវបានអនុវត្តក្រោមកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ ការបង្កើនតួនាទីរាជរដ្ឋាភិបាល ត្រូវធានាដល់ការចូលរៀនប្រកបដោយសមធម៌ សំរាប់សិស្ស-និស្សិត និងគ្រួសារដែលពុំមានលទ្ធភាពបង់ប្រាក់ ដោយមានការធានាគុណភាពសេវាកម្ម និងគុណភាពនៃប្រាក់ដែលបានចំណាយ។ ជាលទ្ធផលអាទិភាពមួយ នឹងត្រូវពង្រីកកម្មវិធីអាហារូបករណ៍សំរាប់សិស្សក្រីក្រដើម្បីធានាអោយពួកគេបានចូលរៀននៅបឋមសិក្សា មធ្យមសិក្សា និងកម្មវិធីបណ្តុះបណ្តាលក្រោយមធ្យមសិក្សា បទពិសោធន៍ដែលទទួលបានពីការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០១-០៥ ដូចជាការផ្តល់អាហារសំរាប់សិស្សបឋមសិក្សា និងកម្មវិធីអាហារូបករណ៍សំរាប់សិស្សថ្នាក់ទី៧ ដល់ថ្នាក់ទី៩ ត្រូវបានផ្តោតលើសិស្សក្រីក្រ ហើយត្រូវបានពង្រីកស្របតាមកម្មវិធីថ្មី គឺកម្មវិធីគាំទ្រសិស្សពូកែនៅក្រោយកំរិតអប់រំមូលដ្ឋាន ដែលសិស្សទាំងនោះមកពីគ្រួសារក្រីក្រ សិស្សស្រី ជនជាតិភាគតិច និងក្រុមងាយរងគ្រោះផ្សេងទៀត។

បទពិសោធន៍មួយដែលបានពីផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០១-០៥ គឺថាធនធានដែលបានបង្កើនមិនគ្រប់លក្ខខណ្ឌ ដើម្បីកែលំអគុណភាព និងស្តង់ដាអប់រំ ។ ដូចនេះអាទិភាពជាយុទ្ធសាស្ត្រមួយសំរាប់*ការកែលំអគុណភាព និងប្រសិទ្ធភាពសេវាអប់រំ* នឹងត្រូវធ្វើអោយប្រាកដថា ស្ថាប័ន និងក្របខ័ណ្ឌអភិបាលកិច្ចល្អបានដំណើរការប្រកបដោយប្រសិទ្ធភាព ដើម្បីធានាដល់កំណែលំអស្តង់ដាអប់រំ ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៤-០៨ បានស្នើអោយមានការបង្កើនលាភការជូនគ្រូបង្រៀន និងកម្មវិធីអាទិភាពដែលផ្តោតលើកំណែលំអគុណភាព (ដូចជា សំភារៈបង្រៀន ការអភិវឌ្ឍគ្រូបង្រៀន)។ កម្មវិធីទាំងនេះផ្សារភ្ជាប់ទៅនឹងឋានានុក្រមនៃវិធានការ

ដែលតំរូវអោយមានការទទួលខុសត្រូវខ្ពស់ (ដូចជា រង្វាយតំលៃការបំពេញការងារបុគ្គលិក) កែលំអតំលាភាព និងការយកចិត្តទុកដាក់ជាចំបងលើលទ្ធផលដែលសំរេចបាន។

នៅក្នុងសាលារៀន យុទ្ធសាស្រ្តគន្លឹះមួយ គឺត្រូវជំរុញអោយមានវប្បធម៌ថ្លៃថ្នូរ តាមរយៈសាលារៀនគំរូ លើកដំកើងគុណធម៌ដែលពាក់ព័ន្ធដល់ស្តង់ដា ការធ្វើតេសទូទាំងប្រទេស ។ សំរាប់គ្រឹះស្ថានអប់រំក្រោយមធ្យមសិក្សានិងគ្រឹះស្ថានបណ្តុះបណ្តាលនានា វិធានការមួយនឹងត្រូវអនុវត្តអោយបានទូលំទូលាយគឺរចនាសម្ព័ន្ធអភិបាលកិច្ចល្អដែលផ្សារភ្ជាប់នឹងការធានាគុណភាព និងនិតិវិធីផ្ទេរក្រេឌីតសិក្សា ។ ច្បាប់អប់រំថ្មី និងកំណែទំរង់លិខិតបទដ្ឋានអប់រំ នឹងផ្តល់ក្របខ័ណ្ឌសំរាប់ក្រសួង និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីប្រតិបត្តិទំនួលខុសត្រូវថ្មី និងសិទ្ធិអំណាចក្នុងសំរេចលទ្ធផលឧត្តមសិក្សា និងស្តង់ដាបណ្តុះបណ្តាលជាតិ ។

សរសស្តម្ភទី ៣ នៃផែនការយុទ្ធសាស្រ្តវិស័យអប់រំឆ្នាំ២០០១-០៥ បានផ្តល់លទ្ធភាពផ្ទេរសិទ្ធអំណាចសំខាន់ៗ ដល់នាយកដ្ឋានជំនាញរបស់ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជននិងកីឡាខេត្ត-ក្រុង ការិយាល័យអប់រំ យុវជន និងកីឡាស្រុក និងសាលារៀន។ យន្តការដំបូង គឺការធ្វើវិមជ្ឈការនៃការគ្រប់គ្រងហិរញ្ញវត្ថុតាមរយៈកម្មវិធីសកម្មភាពជាអាទិភាព។ អាទិភាពសំរាប់ផែនការយុទ្ធសាស្រ្តវិស័យអប់រំឆ្នាំ២០០៤-០៨ នឹងពង្រឹង ពង្រីក*វិធានការកសាងសមត្ថភាពសំរាប់ធ្វើវិមជ្ឈការគ្រប់គ្រងសេវាកម្មអប់រំ*។ សំណើនានាបានបញ្ចូលជំហានមួយចំនួន ដើម្បីពង្រឹងបន្ថែមទៀតនូវផែនការហិរញ្ញវត្ថុនិងការគ្រប់គ្រងនៅគ្រប់កំរិត ស្របជាមួយការលើកកំពស់ប្រព័ន្ធពិនិត្យតាមដានការបំពេញការងារវិស័យ និងកម្មវិធី ។

ក្នុងអំឡុងពេលនៃដំណាក់កាលបន្ទាប់របស់កំណែទំរង់យុទ្ធសាស្រ្តសំខាន់ គឺអនុវត្តវិមជ្ឈការអោយកាន់តែស៊ីជំរៅ និងនៅកំរិតជាច្រើន។ យុទ្ធសាស្រ្តគន្លឹះមួយទៀត គឺពង្រឹងការិយាល័យអប់រំ យុវជន និងកីឡា ស្រុក-ខ័ណ្ឌ ដែលជាកន្លែងដ៏សំខាន់នៅក្នុងការគ្រប់គ្រង និងផ្តល់ពតិមាន។ យុទ្ធសាស្រ្តមួយទៀត គឺលើកកំពស់តួនាទីក្រុមប្រឹក្សាឃុំ-សង្កាត់ និងគណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នា នៅក្នុងការពិនិត្យតាមដាន និងត្រួតពិនិត្យមើលការបំពេញការងាររបស់សាលារៀន។ ផែនការយុទ្ធសាស្រ្តវិស័យអប់រំឆ្នាំ២០០៤-០៨ បានតំរង់ទៅរកការពង្រឹងបន្ថែមទៀតនូវរចនាសម្ព័ន្ធពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធ តាមរយៈគណៈកម្មការជាតិសំរាប់គាំទ្រឃុំ-សង្កាត់ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ និងក្រុមប្រឹក្សាកែទំរង់រដ្ឋបាល។

### ៣.១.២. ការសំរបសំរួលនិងការធ្វើសមាហរណកម្មយុទ្ធសាស្រ្តកំណែទំរង់របស់ផែនការយុទ្ធសាស្រ្ត វិស័យអប់រំ

យុទ្ធសាស្រ្តឆ្លងផ្នែកគឺត្រូវធ្វើសមាហរណកម្មយ៉ាងពេញលេញរវាងការងារអប់រំ យុវជន អប់រំកាយ និងកីឡាទៅក្នុងផែនការយុទ្ធសាស្រ្តវិស័យអប់រំ និងកម្មវិធីគាំទ្រវិស័យអប់រំ។ យុទ្ធសាស្រ្តសំខាន់ៗរួមមាន ១) ពង្រីក

ការអប់រំគុណធម៌ និងសីលធម៌ទៅក្នុងកម្មវិធីសិក្សា ២) ពង្រីកអោយមានការស្ម័គ្រចិត្តចូលរួមរបស់សិស្សានុសិស្ស ដូចជា ការបង្រៀនគ្នាទៅវិញទៅមក ការបង្រៀនអក្សរដល់អ្នកនៅក្នុងភូមិ ៣) ការជួយបន្ថែមក្រៅម៉ោងរបស់សិស្សានុសិស្សក្នុងការថែរក្សាសុខភាពនៅតាមភូមិ គាំទ្រថ្នាក់មត្តេយ្យសិក្សា ជួយដល់ជនចាស់ជរានិងជនពិការ ៤) លើកទឹកចិត្តដល់ការស្ម័គ្រចិត្តពីសំណាក់សាកលវិទ្យាល័យ សាលាគរុកោសល្យ និងសាលាមធ្យមសិក្សាទុតិយភូមិ ដើម្បីផ្តល់ជំនាញរបស់ពួកគេដល់តំបន់ជនបទនិងតំបន់ដាច់ស្រយាល ជាពិសេសក្នុងការងារអប់រំក្រៅប្រព័ន្ធ និងអក្ខរកម្ម និង៤) ពង្រីកកម្មវិធីអប់រំកាយនិងសំភាររូបវ័ន្តកីឡាសំរាប់សហគមន៍នៅទូទាំងប្រទេស ។ ក្នុងយុទ្ធសាស្ត្រនេះ ក្រសួងអប់រំ យុវជននិងកីឡានឹងជំរុញអោយមានភាពជាដៃគូជាមួយវិស័យឯកជន សហគមន៍ជាតិ និងអន្តរជាតិ ។

យុទ្ធសាស្ត្រឆ្លងផ្នែកសំរាប់ពង្រឹងការអនុវត្តគោលនយោបាយ គឺ*បង្កើនការប្រើប្រាស់បច្ចេកវិទ្យាពត៌មាន និងការប្រាស្រ័យទាក់ទង* ដោយអនុវត្តតាមគោលនយោបាយថ្មី ស្តីពីបច្ចេកវិទ្យាពត៌មាន និងការប្រាស្រ័យទាក់ទងរបស់ក្រសួងដែលបានអនុម័តនៅដើមឆ្នាំ២០០៤ ។អាទិភាពមួយទៀត គឺពង្រឹងការគ្រប់គ្រងពត៌មាន ដោយផ្អែកលើបច្ចេកវិទ្យាពត៌មាន និងការប្រាស្រ័យទាក់ទងនៅគ្រប់កំរិត ដែលជាផ្នែកមួយនៃវិធានការធ្វើវិមជ្ឈការ ។ កំណែលំអការចូលរៀន និងគុណភាពត្រូវបានគាំទ្រដោយការផ្តល់កាលានុវត្តភាព ក្នុងការសិក្សាពីចំងាយដោយផ្អែកលើបច្ចេកវិទ្យាពត៌មាន និងការប្រាស្រ័យទាក់ទង (ឧ. ការអភិវឌ្ឍគ្រូបង្រៀន ការសិក្សាពីចំងាយសំរាប់កំរិតបរិញ្ញាប័ត្រជាន់ខ្ពស់ ) ការដាក់អោយអនុវត្តកម្មវិធីការយល់ដឹងអំពីកំព្យូទ័រ នៅក្នុងសាលាមធ្យមសិក្សាទុតិយភូមិ និងគ្រឹះស្ថានក្រោយមធ្យមសិក្សា ។ ជាការគួរ ក្រសួងត្រូវប្រើប្រាស់សមត្ថភាពរបស់ផ្នែកឯកជនក្នុងការកសាងកម្មវិធី និងផ្តល់តាមប្រព័ន្ធផ្សព្វផ្សាយពត៌មានចំរុះ (multi-media) សំរាប់ពង្រីកកម្មវិធីបច្ចេកវិទ្យាពត៌មាន និងការប្រាស្រ័យទាក់ទង និងបង្កើនការយល់ដឹងអំពីជំងឺអេដស៍-ហ៊ីវ ។

យុទ្ធសាស្ត្រផ្តល់ហិរញ្ញប្បទានទូលំទូលាយ នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០១-០៥ នឹងត្រូវពង្រីកបន្ថែមទៀត នូវអន្តរាគមន៍មានលក្ខណៈជាប្រព័ន្ធ (ដូចជា កាត់បន្ថយការចំនាយរបស់មាតាបិតាសិស្ស និងកាត់បន្ថយអត្រាត្រួតថ្នាក់) ។ វិធានការទាំងអស់នេះបានតាក់តែងឡើង ដើម្បីទប់ទល់ និងលុបបំបាត់ការចំណាយរយៈពេលវែងចំពោះរាជរដ្ឋាភិបាល និងមាតាបិតា និងកែលំអលទ្ធភាពនៃនិរន្តរភាពហិរញ្ញប្បទានរយៈពេលវែង ។ អន្តរាគមន៍មួយចំនួននឹងត្រូវបានកំណត់យ៉ាងទូលាយដល់សហគមន៍ និងគ្រួសារក្រីក្របំផុត និងក្រុមជួបការលំបាកធ្ងន់ធ្ងរផ្សេងទៀត (ដូចជា អាហារូបករណ៍សំរាប់សិស្សក្រីក្រ) នៅគ្រប់កំរិត ។

ក្រសួងអប់រំ យុវជន និងកីឡាទទួលស្គាល់ថា ដើម្បីជំរុញការសំរេចលទ្ធផលផែនការជាតិអប់រំសំរាប់ទាំងអស់គ្នា យើងត្រូវប្រមែប្រមូលធនធានបន្ថែមទៀតពីសហគមន៍ និងដៃគូអភិវឌ្ឍន៍នានា ។ សំណើអោយមានការបង់ប្រាក់ពីអ្នកប្រើប្រាស់សំខាន់ៗ សំរាប់គ្រឹះស្ថានបណ្តុះបណ្តាលក្រោយកំរិតអប់រំមូលដ្ឋាន គឺជាផ្នែកមួយនៃ

យុទ្ធសាស្ត្រប្រមូលធនធាន។ ទន្ទឹមនឹងនេះ វាជាការចំណាយបណ្តោះអាសន្នដ៏ច្រើនលើសលប់ ប៉ុន្តែវាជាកម្មវិធីកំណែទំរង់គោលនយោបាយដ៏សំខាន់បំផុត ដែលតំរូវអោយមានការគាំទ្របន្ថែមពីរាជរដ្ឋាភិបាលភ្នាក់ងារអភិវឌ្ឍន៍ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ។

យុទ្ធសាស្ត្រនៃការប្រើប្រាស់ជំនួយពីខាងក្រៅ គឺ*បន្តនិងពង្រីកនីតិវិធីចំរុះ* ដោយគិតទាំងការគាំទ្រថវិកាចរន្ត វិនិយោគមូលធននិងជំនួយបច្ចេកទេស។ នីតិវិធីដ៏សមស្របមួយនឹងត្រូវបានចរចា ដោយផ្អែកលើប្រសិទ្ធភាពនៅក្នុងការអនុវត្តគោលនយោបាយនានា របស់ឯកសារផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ ចំណាយចរន្តដែលមានកំរិតខ្ពស់ នៅក្នុងការកែទំរង់នេះទាមទារអោយមានចំណែកនៃការឧបត្ថម្ភគាំទ្រកាន់តែច្រើនឡើងពីកម្មវិធីជំនួយពីខាងក្រៅ។

យុទ្ធសាស្ត្រពាក់ព័ន្ធមួយទៀត គឺ*បង្កើនការយកចិត្តទុកដាក់លើចំណាយជាមូលធន* ដើម្បីធ្វើអោយមានការកែទំរង់គោលនយោបាយ ។ សំរាប់ការអប់រំមូលដ្ឋាន អាទិភាពចំបងគឺត្រូវកាត់បន្ថយសាលាបឋមសិក្សាមិនគ្រប់កំរិតថ្នាក់ និងពង្រីកសំភាររូបវ័ន្តនៅមធ្យមសិក្សាបឋមភូមិ នៅតាមតំបន់ដែលពុំមានសេវាអប់រំគ្រប់គ្រាន់ ដែលជាកត្តាមួយជំរុញអោយការចូលរៀនបានកាន់តែច្រើន។ នៅមធ្យមសិក្សាទុតិយភូមិ ត្រូវផ្តោតទៅលើសាលាគំរូដែលមានគុណភាព និងស្តង់ដា។ ការអភិវឌ្ឍមូលនិធិ ដើម្បីបំពេញតាមតំរូវការនូវការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឧត្តមសិក្សា និងការស្នាក់នៅរបស់មន្ត្រីអប់រំ ត្រូវបានរៀបចំឡើងដោយពង្រីកភាពជាដៃគូសាធារណៈ ឯកជនកាន់តែច្រើនឡើង។

## ៣.២. ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌

ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៤-០៨ បានពង្រឹងនិងពង្រីកទៅលើយុទ្ធសាស្ត្រសំខាន់ៗទាំងបួននៃផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០១-០៥ សំរាប់ធានាអោយមានសមធម៌នៃការទទួលសេវាអប់រំ ដែលមានសង្ខេប ដូចតទៅ :

- ❋ កាត់បន្ថយការចំណាយដែលជាឧបសគ្គសំរាប់ការអប់រំ ទន្ទឹមនឹងការធ្វើអន្តរាគមន៍ថវិកាសំរាប់កំរិតក្រោយអប់រំមូលដ្ឋាន។
- ❋ កាត់បន្ថយការរៀនត្រួតថ្នាក់និងការបោះបង់ការសិក្សានៅគ្រប់កំរិត ដោយផ្តល់អាទិភាពលើការកែលំអការរៀនសូត្រសំរាប់ថ្នាក់ទី១-៦ ។
- ❋ ជំរុញអោយមានការចូលរួមកាន់តែច្រើនឡើងពីផ្នែកឯកជន សហគមន៍ នៅក្នុងការសិក្សាពីថ្នាក់ទី១០-១២ ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងឧត្តមសិក្សា តាមរយៈការផ្តល់ហិរញ្ញប្បទានសំរាប់ចំណាយមូលធន និងចរន្តផ្អែកទៅតាមតំរូវការ ។

- ⁕ អភិវឌ្ឍសំភាររូបវ័ន្តអប់រំ ដោយផ្តោតទៅលើការកាត់បន្ថយសាលាបឋមសិក្សាមិនគ្រប់កំរិតថ្នាក់ ការពង្រីកការផ្តល់សេវាអប់រំពីថ្នាក់ទី៧-១២ នៅតាមតំបន់ដែលបច្ចុប្បន្ននេះពុំទាន់ទទួលសេវាអប់រំគ្រប់គ្រាន់។
- ⁕ ធ្វើអោយមានសមធម៌ក្នុងការចូលរៀននៅឧត្តមសិក្សា តាមរយៈការងារអភិបាលកិច្ច និងកំណែទំរង់ប្រកបដោយប្រសិទ្ធភាព ។

**ដើម្បីអនុវត្តយុទ្ធសាស្ត្រកាត់បន្ថយការចំណាយសំរាប់ការអប់រំ វិធានការនិងចំណុចដៅសំខាន់ៗរួចមាន:**

- ❑ កាត់បន្ថយវិភាគទានរបស់ឪពុកម្តាយសិស្សចំពោះការអប់រំមូលដ្ឋាន តាមរយៈការលុបបំបាត់វិភាគទានក្រៅផ្លូវការពីថ្នាក់ទី១ដល់ថ្នាក់ទី៩ ដោយបង្កើនប្រាក់បៀវត្សគ្រូបង្រៀន និងផ្តល់ថវិកាដំណើរការសាលារៀន ពីរាជរដ្ឋាភិបាល។ **ចំណុចដៅ** : លុបបំបាត់វិភាគទានក្រៅផ្លូវការនៅថ្នាក់ទី១-៩ នៅទូទាំងប្រទេសនៅដំណាច់ ឆ្នាំ ២០០៨។

- ❑ កសាងលិខិតបទដ្ឋាននានាសំរាប់ធ្វើអោយមានតំលាភាពនៃការប្រមូល និងការគ្រប់គ្រងវិភាគទានរបស់ឪពុកម្តាយសិស្សចំពោះចំណាយក្នុងការអប់រំ និងបណ្តុះបណ្តាលនៅគ្រប់គ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងឧត្តមសិក្សា ទន្ទឹមគ្នានឹងការផ្តល់អាហារូបករណ៍ ការទទួលយកសិស្សក្រីក្រ និងវិធានការផ្សេងៗទៀត។ **ចំណុចដៅ** : លិខិបទដ្ឋាននិងរង្វាន់លើកទឹកចិត្ត អនុវត្តការដាក់ទណ្ឌកម្មត្រូវអនុវត្តនៅចុង ឆ្នាំ ២០០៤។

- ❑ ផ្តល់អាហារូបករណ៍ដល់សិស្សដែលមកពីគ្រួសារក្រីក្រសំរាប់ថ្នាក់ទី៧-១២ និងថ្នាក់ទី៣-៩ ចំពោះកម្មវិធីចូលរៀនឡើងវិញ កម្មវិធីសមមូល និងកម្មវិធីអប់រំជំនាញមូលដ្ឋាន។ **ចំណុចដៅ** : កម្មវិធីពីថ្នាក់ទី៧-៩ ត្រូវបានពង្រីកចាប់ពីឆ្នាំ ២០០៤ និងកម្មវិធីថ្មីចាប់ពីឆ្នាំ២០០៥។

- ❑ ផ្តល់ការលើកទឹកចិត្តសំរាប់អ្នកក្រីក្រ ពិសេសទៅដល់យុវជននៅក្រៅសាលា ដើម្បីអោយពួកគេបានចូលរៀននៅក្នុងកម្មវិធីបណ្តាញមជ្ឈមណ្ឌលសិក្សាសហគមន៍ ដោយរួមបញ្ចូលការប្រើប្រាស់មីក្រូឥណទានដែលបានកំណត់ទុក ។**ចំណុចដៅ** : កម្មវិធីថ្មីត្រូវបានរៀបចំឡើងនៅដំណាច់ឆ្នាំ ២០០៤។

- ❑ ផ្តល់អាហារូបករណ៍សំរាប់សិស្សពូកែដល់សិស្សមកពីគ្រួសារក្រីក្រ សំរាប់មធ្យមសិក្សាទុតិយភូមិការបណ្តុះ បណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងឧត្តមសិក្សា ដោយផ្អែកលើលទ្ធផលប្រលងនៅថ្នាក់ទី៩ និងទី១២ ។ **ចំណុចដៅ** : កម្មវិធីនេះរៀបចំនៅដំណាច់ឆ្នាំ២០០៤ ។

- ❑ ពិនិត្យឡើងវិញលើការផ្តល់ប្រាក់ឧបត្ថម្ភអាហារូបករណ៍ដល់គរុសិស្ស-និស្សិត ដែលបានជ្រើសសំរាំងសំរាប់ការចូលរៀននៅសាលាគរុកោសល្យ ដោយផ្អែកលើការយល់ព្រមជ្រើសរើសយកបុស្តិ៍នៅតំបន់

ដាច់ស្រយាល និងតំរូវការនៅតំបន់ខ្វះគ្រូនៅពេលចប់វគ្គបណ្តុះបណ្តាលគ្រូ ។ ចំណុចដៅ : ពិនិត្យលើកម្មវិធីពង្រាយគ្រូ និងកំណត់ចំណុចដៅនៅដំណាច់ឆ្នាំ២០០៤។

**ដើម្បីអនុវត្តយុទ្ធសាស្ត្រកាត់បន្ថយការត្រួតថ្នាក់និងការបោះបង់ការសិក្សា វិធានការនិងចំណុចដៅសំខាន់ៗរួមមាន:**

- ❑ បង្កើនអត្រាឡើងថ្នាក់ពីថ្នាក់ទី១-៦ និងអត្រាឆ្លងភូមិសិក្សាពីថ្នាក់ទី៦-៧ ព្រមទាំងអត្រាឡើងពីថ្នាក់ទី៧-៩ ដោយផ្សារភ្ជាប់ទៅនឹងការពង្រីក និងអនុវត្តថ្នាក់បំប៉នប្រកបដោយប្រសិទ្ធភាព គួបផ្សំនឹងការវាយតំលៃលទ្ធផលនៃការសិក្សារបស់សិស្សជាបន្តបន្ទាប់ តាមដំណាក់កាល និងការពិនិត្យតាមដានស្តង់ដា។ ចំណុចដៅ : អត្រាឡើងថ្នាក់ទី១-៦ស្មើ៩៥% និងអត្រាឡើងថ្នាក់ទី៧-៩ស្មើ៨៥% អត្រាឆ្លងភូមិសិក្សាពីថ្នាក់ទី៦ទៅទី៧ស្មើ ៩៥% នៅឆ្នាំ២០០៨។

- ❑ កាត់បន្ថយអត្រាបោះបង់ការសិក្សាពីថ្នាក់ទី១-ទី១២ តាមរយៈការផ្តល់ប្រាក់ឧបត្ថម្ភ អាហារូបករណ៍សំរាប់សិស្សក្រីក្របំផុត គួបផ្សំនឹងវិធានការលើកទឹកចិត្តគ្រប់រូបភាព ដូចជាការផ្តល់អាហារសំរន់ពេលព្រឹកនៅសាលារៀន ។ ចំណុចដៅ : អត្រាបោះបង់ការសិក្សាអតិបរមា ៥% នៅឆ្នាំ២០០៨។

- ❑ កែលំអលិខិតបទដ្ឋានអោយកុមារអាយុ៦ឆ្នាំចូលរៀនថ្នាក់ទី១ និងបង្កើនឱកាសការអភិវឌ្ឍថែទាំនិងអប់រំកុមារតូច សំរាប់កុមារអាយុ៥ឆ្នាំ។ ចំណុចដៅ : សិស្សចូលរៀនថ្នាក់ទី១ អាយុ ៦ឆ្នាំ ៩៥%នៅឆ្នាំ ២០០៨។

**ដើម្បីអនុវត្តយុទ្ធសាស្ត្រជំរុញអោយមានការចូលរួមកាន់តែខ្លាំងក្លាពីសំណាក់ផ្នែកឯកជន-សហគមន៍ វិធានការនិងចំណុចដៅសំខាន់ៗរួមមាន :**

- ❑ រៀបចំគោលនយោបាយនិងផែនការយុទ្ធសាស្ត្រទូទាំងវិស័យ ស្តីពីភាពជាដៃគូសាធារណៈ និងឯកជនសំរាប់អនុវិស័យនិងកម្មវិធីអប់រំនានារួមមាន សំរាប់ថ្នាក់ទី១០-១២ សំរាប់ផ្នែកឧត្តមសិក្សា សំរាប់ការអភិវឌ្ឍ និងថែទាំកុមារតូច និងសំរាប់មជ្ឈមណ្ឌលសិក្សាសហគមន៍ ។ ចំណុចដៅ : យុទ្ធសាស្ត្រប្រតិបត្តិនិងផែនការសកម្មភាពលំអិតនៅចុងឆ្នាំ ២០០៤។

- ❑ ផ្តល់កម្មវិធីលើកទឹកចិត្តសំរាប់អ្នកផ្តល់សេវាផ្នែកឯកជន ជាពិសេសសំរាប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ តាមរយៈកំណែទំរង់គណៈកម្មការជាតិបណ្តុះបណ្តាល (National Training Board) ពង្រីកមូលនិធិជាតិសំរាប់ការបណ្តុះបណ្តាល (National Training Fund) និងប្រើប្រាស់មូលនិធិអភិវឌ្ឍន៍ផ្សេងៗទៀត ។ ចំណុចដៅ : ពង្រីកគណៈកម្មការជាតិបណ្តុះបណ្តាល និងមូលនិធិជាតិសំរាប់ការបណ្តុះបណ្តាលចាប់ពីឆ្នាំ ២០០៥ តទៅ។

- ជំរុញនិងពង្រីកការផ្តល់សេវាអប់រំផ្នែកឯកជននៅគ្រប់កំរិត តាមរយៈការបង្កើតអោយមានច្បាប់និងលិខិតបទដ្ឋាននានាច្បាស់លាស់ និងការរៀបចំការធានាគុណភាព ។ **ចំណុចដៅ** : មានច្បាប់គ្រប់គ្រាន់ចាប់ពីឆ្នាំ ២០០៥តទៅ។

- រៀបចំនិងជំរុញអោយមានការទទួលស្គាល់ ការផ្ទេរក្រេឌីតសិក្សាពីគ្រឹះស្ថានសិក្សាមួយទៅគ្រឹះស្ថានសិក្សាមួយផ្សេងទៀត ។ **ចំណុចដៅ** : សំរេចអោយបាននៅឆ្នាំ២០០៥ ។

- បង្កើតគណៈគ្រប់គ្រងដោយមានការចូលរួមទូលំទូលាយសំរាប់ TVET ឧត្តមសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍។ **ចំណុចដៅ** : ការរៀបចំចាត់ចែងអភិបាលកិច្ចនិងតំណាងថ្មីនឹងចាប់ផ្តើមនៅដំណាច់ឆ្នាំ២០០៤ ។

**ដើម្បីអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍសំភាររូបវ័ន្តអប់រំ វិធានការនិងចំណុចដៅសំខាន់ៗរួមមាន :**

- ផ្តល់ថ្នាក់រៀនបន្ថែមថ្មីទន្ទឹមនឹងការបង្រៀនថ្នាក់គួបនៅតាមភូមិ និងឃុំ ដែលគ្មានសាលាគ្រប់កំរិតពីថ្នាក់ ទី១-៦ ។ **ចំណុចដៅ** : គ្របដណ្តប់ ៩៥% នៅឆ្នាំ២០០៨។

- ប្រើប្រាស់សាលារៀនកំរិតមូលដ្ឋានថ្នាក់ទី១-៩ តាមរយៈការផ្តល់ថ្នាក់រៀនបន្ថែមនៅតាមឃុំដែលគ្មានអនុវិទ្យាល័យ (ទី៧-ទី៩) ។ **ចំណុចដៅ** : គ្របដណ្តប់ ៩៥% នៅឆ្នាំ២០០៨។

- ផ្តល់ថ្នាក់រៀនបន្ថែមសំរាប់ថ្នាក់ទី១-៩ និងថ្នាក់ទី១០-១២ ដល់សាលាដែលបច្ចុប្បន្ន ឬដែលបានប៉ាន់ស្មាន ថាមានសិស្សច្រើនលើសលុប។ **ចំណុចដៅ** : ផែនការសកម្មភាពតាមដំណាក់កាល និងការកំណត់លក្ខណៈវិនិច្ឆ័យនៅចុងឆ្នាំ ២០០៤។

- បង្កើតមូលនិធិសមស្របសំរាប់អភិវឌ្ឍសាលាមធ្យមសិក្សា សាលាបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងឧត្តមសិក្សា ដើម្បីឆ្លើយតបទៅនឹងតំរូវការចូលរៀន ។ **ចំណុចដៅ** : មូលនិធិ និងលក្ខណៈវិនិច្ឆ័យត្រូវរៀបចំឡើងនៅដើមឆ្នាំ២០០៥ ហើយរដ្ឋខិតខំប្រឹងប្រែងក្នុងការផ្តល់មូលនិធិដល់សាលាមធ្យមសិក្សាទុតិយភូមិគំរូថ្នាក់ទី១០-១២ ។

- ពិនិត្យឡើងវិញពីតំរូវការសាងសង់អន្តេវាសិកដ្ឋានសំរាប់និស្សិតស្រី នៅឧត្តមសិក្សា។ រៀបចំផែនការនៅដើមឆ្នាំ២០០៥ ។

- បង្កើតមូលនិធិសំរាប់ការស្នាក់នៅរបស់បុគ្គលិកក្រសួងអប់រំ យុវជន និងកីឡា រួមមានគំរោងថវិកាកម្ចីសំរាប់សាងសង់ផ្ទះស្នាក់នៅ និងរៀបចំលក្ខណៈវិនិច្ឆ័យសមស្របទាក់ទិននឹងគោលនយោបាយពង្រាយគ្រូការផ្ទេរកន្លែងធ្វើការ ។ ចំណុចដៅ : មូលនិធិបង្កើតនៅដើមឆ្នាំ ២០០៥។

**ដើម្បីអនុវត្តយុទ្ធសាស្ត្រធ្វើអោយមានសមធម៌នៃការចូលរៀននៅឧត្តមសិក្សា វិធានការនិងចំណុចដៅសំខាន់ៗរួមមាន :**

- ❑ បង្កើតមជ្ឈមណ្ឌលថ្មីមួយនៅសំរាប់បំរើដល់ការដាក់ពាក្យចូលរៀននៅឧត្តមសិក្សា ឆ្លើយតបតាមការផ្តល់អាហារូបករណ៍ ។បង្កើតមូលដ្ឋានស្ថិតិសំរាប់កំណត់ល័ក្ខខ័ណ្ឌចូលរៀននៅឧត្តមសិក្សា និងមុខជំនាញដែលសិស្ស-និស្សិតចូលចិត្តសំដៅឆ្លើយតបនឹងតំរូវការទីផ្សារ ។ អនុវត្តកម្មវិធីតំរង់ទិស (Orientation program)សំរាប់សិស្សដែលប្រលងជាប់ថ្នាក់ទី១២ ចាប់ពីឆ្នាំ២០០៥តទៅ ។
- ❑ កំណត់ច្បាស់អំពីតំរូវការនៃការសិក្សាថ្នាក់ត្រៀមជាមូលដ្ឋាន (Foundation Year) នៅឆ្នាំ២០០៤ និង ការចាប់ផ្តើមអនុវត្តការសិក្សាថ្នាក់ត្រៀមជាមូលដ្ឋាននេះនៅឆ្នាំ២០០៥ តាមគ្រឹះស្ថានឧត្តមសិក្សានៅទីក្រុងភ្នំពេញ និងពង្រីកជាបន្តបន្ទាប់នៅខេត្ត-ក្រុង ដោយប្រើប្រាស់គ្រប់រូបភាពនៃការបង្រៀន និងរៀន ។ **ចំណុចដៅ :** ចំនួនសិស្សសរុបនៅតាម ខេត្តមាន ១៥,០០០នាក់ ត្រឹមឆ្នាំ២០០៨ ។
- ❑ ពង្រឹងធនធាន និងសមត្ថភាព ACC ដើម្បីអភិវឌ្ឍន៏ការផ្ទេរក្រេឌីតសិក្សា ដែលរួមមាន ការវាយតំលៃកម្មវិធីបណ្តុះបណ្តាលគ្រូ និងគុណវុឌ្ឍិ ដែលផ្តល់ការបណ្តុះបណ្តាលដោយមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ អោយសំរេចបាននៅឆ្នាំ ២០០៥ ។
- ❑ បង្កើតអោយមានអាហារូបករណ៍ រួមជាមួយផែនការប្រាក់កម្ចីសំរាប់និស្សិតក្រីក្រ ។ **ចំណុចដៅ :** និស្សិត ជាអ្នកទទួលផលចំនួន២០.០០០នាក់ (៥០% ជាអាហារូបករណ៍ និង ៥០%ជាប្រាក់កំចី) ។

សកម្មភាពជាយុទ្ធសាស្ត្រទូទាំងវិស័យ ដើម្បីធានាសមធម៌នៃការទទួលសេវាអប់រំ និងដំណាក់កាលសំខាន់ក្នុងអំឡុងពេល២០០៤-០៨ មានសង្ខេបជូនក្នុងឧបសម្ព័ន្ធ ១ ។

## ៣.៣. បង្កើនគុណភាពនិងប្រសិទ្ធភាពសេវាកម្មអប់រំ

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០០៤-០៨ មានយុទ្ធសាស្ត្រចំនួន៦ ដើម្បីធានាដល់ការកែលំអគុណភាព និងប្រសិទ្ធភាពសេវាអប់រំ ។ យុទ្ធសាស្ត្រទាំងនោះ ផ្តោតលើការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់បុគ្គលិក និងការបំពេញការងារ ពង្រីកការទទួលខុសត្រូវ តាមរយៈការពិនិត្យតាមដានការបំពេញការងាររបស់សាលារៀន បុគ្គលិក និងការសិក្សារបស់សិស្ស ។

- ❈ ការបំពេញការងារនិងប្រសិទ្ធភាពនៃសេវាអប់រំ
- ❈ ធ្វើវិមជ្ឈការការងារគ្រប់គ្រងសាលារៀននិងគ្រឹះស្ថានសិក្សា
- ❈ ផ្គត់ផ្គង់សំភារៈសិក្សានិងការកែទំរង់កម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាព
- ❈ ធ្វើវិមជ្ឈការការងារគ្រប់គ្រងនិងការកសាងផែនការអភិវឌ្ឍន៏គ្រូបង្រៀន

- ❋ កែលំអការពិនិត្យតាមដានការបំពេញការងាររបស់គ្រឹះស្ថានសិក្សា សាលារៀន និងការសិក្សារបស់សិស្ស
- ❋ ការកែលំអគុណភាពនិងប្រសិទ្ធភាពនៅឧត្តមសិក្សា

**ដើម្បីអនុវត្តយុទ្ធសាស្ត្របំពេញការងារនិងប្រសិទ្ធភាពនៃសេវាអប់រំ វិធានការនិងចំណុចដៅសំខាន់ៗរួមមាន :**

- ❑ កែលំអប្រសិទ្ធភាពក្នុងការកសាងផែនការនិងដាក់ពង្រាយបុគ្គលិកបង្រៀន និងមិនបង្រៀននៅសាលាបឋមសិក្សានិងមធ្យមសិក្សាតាមរយៈ (ក)កែលំអនិយាមប្រើប្រាស់បុគ្គលិកផ្អែកលើផលធៀបសិស្ស-គ្រូ (ខ)ចេញគោលការណ៍ណែនាំអំពីការប្រើប្រាស់បុគ្គលិកនៅតាមសាលារៀន (គ)ពង្រឹងយន្តការក្នុងការអនុវត្តតាមនិយាម ។ **ចំណុចដៅ** : នៅបឋមសិក្សាផលធៀបសិស្ស-គ្រូ ៥០ និងផលធៀបសិស្ស-បុគ្គលិកមិនបង្រៀន៣៩០ ។ នៅមធ្យមសិក្សាផលធៀបសិស្ស-គ្រូ ៤០-៤៥នាក់ និងផលធៀបសិស្ស-បុគ្គលិកមិនបង្រៀន ២៧៥។ នៅក្រោយមធ្យមសិក្សាផលធៀបសិស្ស-គ្រូ២៥-៣០ និងផលធៀបសិស្ស-បុគ្គលិកមិន បង្រៀន ២០០ នៅត្រឹមឆ្នាំ ២០០៨។
- ❑ ដាក់ពង្រាយនិងពង្រាយឡើងវិញបុគ្គលិកបង្រៀននិងមិនបង្រៀន អោយទៅបង្រៀននៅតាមសាលារៀនដែលខ្វះគ្រូ តាមរយៈការផ្តល់រង្វាន់លើកទឹកចិត្តផ្សេងៗពីគ្នា និងការកំណត់ប៉ុស្តិ៍ជាក់លាក់សំរាប់គ្រូចេញថ្មីអោយទៅសាលារៀនដែលខ្វះគ្រូ ។ **ចំណុចដៅ** : កែលំអគោលការណ៍ណែនាំនៃការកំណត់ប៉ុស្តិ៍នៅចុងឆ្នាំ២០០៤ ដោយធ្វើការកំណត់ប៉ុស្តិ៍និងការពង្រាយឡើងវិញជាអប្បបរមា ៣៥០០ នាក់ក្នុង មួយឆ្នាំចាប់ពីឆ្នាំ ២០០៥។
- ❑ បង្កើនប្រាក់បៀវត្សសំរាប់អ្នកគ្រប់គ្រងអប់រំ គ្រូឧទ្ទេស និងបុគ្គលិកបង្រៀនទាំងអស់ តាមរយៈគុណសម្បត្តិនៃការបំពេញការងារ ។ ដំឡើងប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភផ្សេងៗទៀត និងប្រាក់គរុកោសល្យ ដោយផ្តល់អាទិភាពទៅលើគ្រូនៅបឋមសិក្សា ។ **ចំណុចដៅ** : រៀបចំផែនការរៀបចំដំឡើងបៀវត្ស តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ចាប់ពីឆ្នាំ២០០៤។
- ❑ បង្កើតប្រព័ន្ធវាយតំលៃការបំពេញការងាររបស់បុគ្គលិកទូទាំងប្រទេស និងបទបញ្ញត្តស្តីពីស្តង់ដាអប្បបរមានៃការបំពេញការងារ និងបន្ទុកការងាររបស់បុគ្គលិក ដើម្បីជាមូលដ្ឋានសំរាប់ការដំឡើងឋានៈ និងបង្កើនប្រាក់បៀវត្ស ។ **ចំណុចដៅ** : គោលការណ៍ណែនាំសំរាប់ប្រតិបត្តិត្រូវរៀបចំនៅចុងឆ្នាំ២០០៤ ការវាយតំលៃទៅលើគ្រូនៅបឋមសិក្សាធ្វើនៅឆ្នាំ២០០៥ និងធ្វើទូទាំងប្រទេសនៅត្រឹមឆ្នាំ២០០៧។
- ❑ កំណត់តួនាទីនិងភារកិច្ចរបស់វិទ្យាស្ថានជាតិអប់រំសំរាប់កម្មវិធីអភិវឌ្ឍមន្ត្រីរាជការរួមមានមន្ត្រីផែនការមន្ត្រីគ្រប់គ្រងអប់រំ និងមន្ត្រីបច្ចេកទេសផ្សេងទៀតគ្រប់លំដាប់ថ្នាក់ ដោយផ្សារភ្ជាប់លទ្ធភាពដំឡើង

តួនាទី និងកាំប្រាក់ ជាពិសេសនាយកសាលារៀនដែលជាក្រុមអាទិភាពទីមួយ ។**ចំណុចដៅ** ៖ រៀបចំវិទ្យាស្ថានជាតិអប់រំនិងផែនការបណ្តុះបណ្តាលត្រឹមចុងឆ្នាំ២០០៤និងចាប់ផ្តើមអនុវត្តពីឆ្នាំ២០០៥តទៅ

**ដើម្បីអនុវត្តយុទ្ធសាស្រ្តធ្វើវិមជ្ឈការការងារគ្រប់គ្រងសាលារៀននិងគ្រឹះស្ថានសិក្សា វិធានការនិងចំណុចដៅសំខាន់ៗ រួចមាន ៖**

- រៀបចំកិច្ចព្រមព្រៀងស្តីពីការបំពេញការងារប្រចាំឆ្នាំ និងរបាយការណ៍នៅគ្រប់លំដាប់ថ្នាក់ ដោយមានយន្តការទទួលខុសត្រូវរួមជាមួយអភិបាលខេត្ត-ក្រុង ក្រុមប្រឹក្សាឃុំ-សង្កាត់ សហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។ **ចំណុចដៅ** ៖ គោលការណ៍ណែនាំស្តីពីការបំពេញការងារ នៅត្រឹមដើមឆ្នាំ២០០៥ និងចាប់ផ្តើមអនុវត្តនៅសាលាបឋមសិក្សានិងមធ្យមសិក្សា នៅចុងឆ្នាំ ២០០៥ ។
- បង្កើតយន្តការថ្មីនៃការធ្វើផែនការផ្នែកហិរញ្ញវត្ថុ និងយន្តការទទួលខុសត្រូវលើថវិកាដំណើរការសាលាបឋមសិក្សានិងមធ្យមសិក្សា ដោយមានគោលការណ៍ណែនាំ ស្តីពីការចូលរួមនៅក្នុងការគ្រប់គ្រងសាលារៀនរួមគ្នា ពីសំណាក់មាតាបិតានិងសហគមន៍ ។ **ចំណុចដៅ** ៖ កែលំអគោលការណ៍ណែនាំដែលនឹងត្រូវរៀបចំនៅចុងឆ្នាំ២០០៤ ជាមួយនឹងការផ្តល់របាយការណ៍បានទាន់ពេលវេលាពីសាលារៀន និងអង្គភាពគ្រប់គ្រងថវិកា ថ្នាក់ស្រុកទាំងអស់នៅក្នុងឆ្នាំ២០០៥។
- ប្រែក្លាយគ្រឹះស្ថាន TVET និងឧត្តមសិក្សាសាធារណៈដែលបានជ្រើសរើសទៅជាគ្រឹះស្ថានរដ្ឋបាលសាធារណៈ ដោយមានគោលការណ៍ណែនាំពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីការរកប្រាក់ចំណូល ការជួល និងប្រើប្រាស់ ទទីមនឹងនោះមានការរៀបចំអភិបាលកិច្ចសាលាសាធារណៈ និងឯកជន។ **ចំណុចដៅ** ៖ គ្រប់គ្រឹះស្ថានសិក្សាបានប្រែក្លាយជាគ្រឹះស្ថានសិក្សារដ្ឋបាលសាធារណៈ ដោយមានគណៈកម្មការគ្រប់គ្រង និង ចំណាត់តាំងការទទួលខុសត្រូវ ដល់ឆ្នាំ ២០០៥-០៦ ។
- កែលំអការគ្រប់គ្រងនិងការកសាងផែនការប្រតិបត្តិផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុនៅថ្នាក់ស្រុក តាមរយៈ អង្គភាពគ្រប់គ្រងថវិកា (BMC) ដោយកំណត់ការទទួលខុសត្រូវកាន់តែច្រើនឡើងសំរាប់ការកសាងកម្មវិធីជាអាទិភាព និងកម្មវិធីផ្សេងៗទៀត។ **ចំណុចដៅ** ៖ កែលំអសំភាររូបវ័ន្តនៅ BMC ថ្នាក់ស្រុក ហើយ BMC ទាំងអស់ប្រតិបត្តិការងារដោយពេញលេញនៅត្រឹមចុងឆ្នាំ២០០៥ ។
- កែលំអវិសាលភាពនៃការធ្វើសវនកម្មផ្ទៃក្នុងចំពោះ BMC សាលារៀន គ្រឹះស្ថានដទៃទៀត ។ ពង្រឹងប្រតិបត្តិការសវនកម្មនិងការផ្តល់បុគ្គលិកនៅថ្នាក់កណ្តាលនៃក្រសួងអប់រំ យុវជន និងកីឡា ។ **ចំណុចដៅ** ៖ ផែនការសវនកម្មរយៈពេល៥ឆ្នាំនឹងត្រូវបញ្ចប់នៅត្រឹមចុងឆ្នាំ២០០៤ គ្រប់ BMCs សាលារៀន គ្រឹះស្ថាន និងកម្មវិធីនានាត្រូវបានធ្វើសវនកម្ម ត្រឹមចុងឆ្នាំ២០០៨។

**ដើម្បីអនុវត្តយុទ្ធសាស្ត្រផ្គត់ផ្គង់សំភារសិក្សានិងកែទំរង់កម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាព វិធានការនិងចំណុចដៅ សំខាន់ៗរួមមាន :**

- ❑ បញ្ចប់ការតាក់តែងគោលនយោបាយកម្មវិធីសិក្សាប្រកបដោយចីរភាព ការបង្កើនម៉ោងបង្រៀន ទាំងកម្មវិធីក្នុងនិងក្រៅសាលារៀន ពិសេសកម្មវិធីបំណិនជីវិត។ **ចំណុចដៅ :** ក្របខ័ណ្ឌកម្មវិធីសិក្សាបានបញ្ចប់ នៅពាក់កណ្តាលឆ្នាំ២០០៥ និងបានអនុវត្តនៅពាក់កណ្តាលឆ្នាំ ២០០៨។
- ❑ បន្តផ្គត់ផ្គង់ដោយសមធមិសៀវភៅសិក្សាគោល និងសំភារៈបន្ថែមសំរាប់ថ្នាក់ទី១-១២ ដោយមានការគាំទ្រផ្នែកថវិកាប្រចាំឆ្នាំពីរាជរដ្ឋាភិបាល។ **ចំណុចដៅ :** សំរាប់ថ្នាក់ទី ១-៩ សិស្ស១នាក់ សៀវភៅ១ក្បាលក្នុង១ មុខវិជ្ជា និងសំរាប់ថ្នាក់ទី១០-១២ សិស្ស២នាក់ សៀវភៅ១ក្បាល និងសិស្ស ១នាក់ ១ក្បាល១មុខវិជ្ជា សំរាប់តំបន់ដាច់ស្រយាល ។
- ❑ ផ្តល់សំភារសិក្សាអោយបានគ្រប់គ្រាន់ ដល់មជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ គ្រឹះស្ថានឧត្តមសិក្សា អប់រំក្រៅប្រព័ន្ធនិងអក្ខរកម្ម និងសាលាគរុកោសល្យនិងវិក្រឹតការខេត្ត-ក្រុង ព្រមទាំងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ តាមរយៈការកែលំអយន្តការហិរញ្ញប្បទាន រួមទាំងការឧបត្ថម្ភផ្សេងទៀតដល់សិស្សក្រីក្រ។ **ចំណុចដៅ :** រៀបចំផែនការរួចរាល់នៅចុងឆ្នាំ២០០៤ ។
- ❑ បន្តធ្វើវិមជ្ឈការការកសាងផែនការនិងការគ្រប់គ្រងសំភារៈបង្រៀនអោយបានល្អ និងគ្រប់គ្រាន់ ជាពិសេសមុខវិជ្ជាវិទ្យាសាស្ត្រ តាមរយៈការបែងចែកថវិការៀងរាល់ឆ្នាំ ទៅអោយសាលារៀននិងផ្ទេរការទទួល ខុសត្រូវទៅនាយកដ្ឋានបឋមសិក្សា និងមធ្យមសិក្សា។ **ចំណុចដៅ :** កម្មវិធីបន្តនៅឆ្នាំ២០០៤។
- ❑ ពិនិត្យឡើងវិញការផ្តល់ហិរញ្ញប្បទានប្រកបដោយចីរភាពរយៈពេលខ្លី និងប្រព័ន្ធផ្គត់ផ្គង់សំភារបង្រៀន រួមមានការពិនិត្យឡើងវិញពីតួនាទីនិងឋានៈនៃគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ។ **ចំណុចដៅ :** ការពិនិត្យឡើងវិញនៅពាក់កណ្តាលឆ្នាំ ២០០៤ ដោយពិចារណាអំពីយុទ្ធសាស្ត្ររយៈពេលវែង។
- ❑ រៀបចំយុទ្ធសាស្ត្ររយៈពេលមធ្យមនិងវែង សំរាប់ពង្រីកលក្ខណៈពាណិជ្ជកម្មនៃការនិពន្ធនិងបោះពុម្ពសៀវភៅសិក្សានិងផ្គត់ផ្គង់នៅកម្ពុជា ដើម្បីអោយមានសៀវភៅសិក្សាសំបូរបែបងាយស្រួលជ្រើសរើស និងការកំណត់តំលៃដែលមានការប្រកួតប្រជែងពីសំណាក់ក្រុមហ៊ុននានា។ **ចំណុចដៅ :** យុទ្ធសាស្ត្រថ្មីនឹងរៀបចំនៅចុងឆ្នាំ ២០០៥។

**ដើម្បីអនុវត្តយុទ្ធសាស្ត្រធ្វើវិមជ្ឈការការងារគ្រប់គ្រងនិងកសាងផែនការអភិវឌ្ឍន៍គ្រូបង្រៀន វិធានការនិងចំណុចដៅសំខាន់ៗរួមមាន :**

- ពង្រឹងផែនការផ្តល់គ្រូបង្រៀនក្នុងការពង្រីកលទ្ធភាពចូលរៀនរបស់សិស្ស និងកែលំអគោលការណ៍ណែនាំការពង្រាយបុគ្គលិក ដោយផ្តល់សិទ្ធិទៅអោយថ្នាក់ខេត្តនិងស្រុក ។ **ចំណុចដៅ** : គោលការណ៍ណែនាំបានកែលំអនៅឆ្នាំ ២០០៤។
- បង្កើនការផ្តល់សិទ្ធិទៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូនិងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ក្នុងការធ្វើផែនការបណ្តុះបណ្តាលគ្រូថ្មី ស្របទៅនឹងគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។ **ចំណុចដៅ** : សិទ្ធិអំណាចទទួលខុសត្រូវ និងគោលការណ៍ណែនាំដែលបានកែលំអត្រូវអនុវត្តនៅឆ្នាំ ២០០៤ ។
- ពង្រឹងការកែលំអគុណភាពនិងភាពពាក់ព័ន្ធនៅគ្រប់កំរិត និងគ្រប់ប្រភេទនៃកម្មវិធីបណ្តុះបណ្តាលគ្រូ (PRESET) តាមរយៈការកែទំរង់កម្មវិធីសំរាប់បណ្តុះបណ្តាលគ្រូ ដូចជាពហុមុខវិជ្ជា ថ្នាក់គួប ការបង្រៀនជនជាតិភាគតិច បំណិនជីវិត ។ល។ និងការអភិវឌ្ឍបុគ្គលិក។ **ចំណុចដៅ** : បន្តកែលំអកម្មវិធី (PRESET) នៅក្នុងឆ្នាំ ២០០៤។
- ធានាការផ្គត់ផ្គង់គ្រូបង្រៀនអោយបានគ្រប់គ្រាន់ ដល់តំបន់ដាច់ស្រយាល និងតំបន់ជនជាតិភាគតិច តាមរយៈការជ្រើសរើសគរុសិស្សពីតំបន់ទាំងនោះ ផ្តល់ប្រាក់លើកទឹកចិត្ត និងភាពទន់ភ្លន់ក្នុងល័ក្ខខ័ណ្ឌជ្រើសរើសគរុសិស្សចូលរៀននៅក្នុងកម្មវិធី (PRESET) ។ **ចំណុចដៅ** : ផែនការសកម្មភាពបានកែលំអ នៅចុងឆ្នាំ ២០០៤។
- កែលំអភាពឆ្លើយតបរបស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ចំពោះតំរូវការវិក្រឹតការ បំប៉នគ្រូបង្រៀន តាមរយៈការបង្កើនស្វ័យភាពការងារ ដើម្បីដំណើរការកម្មវិធីអោយស្របទៅនឹងគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ។ **ចំណុចដៅ** : សាលាគរុកោសល្យខ្នាតតូចចំនួន៦ ត្រូវបានសង់រួចរាល់ នៅត្រឹមចុងឆ្នាំ២០០៥ សាលាគរុកោសល្យនីមួយៗត្រូវរៀបចំផែនការសកម្មភាពវិក្រឹតការបំប៉នគ្រូបង្រៀន នៅដំណាច់ឆ្នាំ ២០០៥។
- ពង្រីកកម្មវិធីអភិវឌ្ឍន៍ និងបណ្តុះបណ្តាលគ្រូបង្រៀនសំរាប់សាលាគរុកោសល្យនិងវិក្រឹតការខេត្ត-ក្រុង មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ មជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងគ្រឹះស្ថានឧត្តមសិក្សា តាមរយៈកម្មវិធីរបស់វិទ្យាស្ថានជាតិអប់រំ និងកម្មវិធីនានា។ **ចំណុចដៅ** : ផែនការរៀបចំនៅចុងឆ្នាំ ២០០៤ ។
- ជំរុញយុទ្ធសាស្ត្របង្កើនការបណ្តុះបណ្តាលគ្រូ តាមរយៈការបណ្តុះបណ្តាលក្រោយឧត្តមសិក្សាក្នុង និងក្រៅប្រទេស។ **ចំណុចដៅ** : បង្កើនការចូលរួមរបស់វិទ្យាស្ថានជាតិអប់រំ និងមន្ត្រីអប់រំនៅតាមសាលាគរុកោសល្យនិងវិក្រឹតការខេត្ត-ក្រុង អោយទៅជាសាស្ត្រាចារ្យកំរិតបណ្ឌិត និងអនុបណ្ឌិតចាប់ពីឆ្នាំ ២០០៥ ។

**ដើម្បីអនុវត្តយុទ្ធសាស្ត្រកែលំអការពិនិត្យតាមដានការបំពេញការងាររបស់សាលារៀន និងការសិក្សារបស់សិស្ស វិធានការនិងចំណុចដៅសំខាន់ៗរួមមាន :**

- កំណត់ស្តង់ដាទូទៅនៃលទ្ធផលសិក្សារបស់សិស្សសំរាប់ថ្នាក់នីមួយៗ ពីថ្នាក់ទី១-១២ និងធានាការយល់ដឹងស្តង់ដាអប្បបរមាដែលមានការទទួលស្គាល់ពីគ្រូបង្រៀន ឪពុកម្តាយ និងអ្នកពាក់ព័ន្ធដទៃទៀត តាមរយៈកម្មវិធីពតិមានការអប់រំនិងការប្រាស្រ័យទាក់ទង (IEC) ទូទាំងប្រទេស ។ **ចំណុចដៅ:** ការរៀបចំស្តង់ដា នៅចុងឆ្នាំ ២០០៤ និងសាកល្បងនៅឆ្នាំ២០០៥ ។
- ពង្រឹងគោលនយោបាយចូលរៀននៅឧត្តមសិក្សា និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ តាមរយៈបង្កើនការប្រើប្រាស់លទ្ធផលប្រលងថ្នាក់ទី១២ សំរាប់ពិនិត្យមើលលទ្ធភាពចូលរៀន ។ **ចំណុចដៅ** : ធ្វើការពិនិត្យឡើងវិញនិងផែនការពេលអនាគតចាប់ពីចុងឆ្នាំ ២០០៤ តទៅ ។
- បង្កើនប្រសិទ្ធភាពកសាងផែនការ និងគ្រប់គ្រងក្នុងការពិនិត្យតាមដានការបំពេញការងាររបស់សាលារៀន តាមរយៈការកំណត់ឱ្យច្បាស់លាស់អំពីតួនាទីរបស់អធិការថ្នាក់កណ្តាល ខេត្ត-ក្រុង និងស្រុក-ខ័ណ្ឌ និងកំរងសាលារៀន ។ **ចំណុចដៅ** : កែលំអផែនការប្រើប្រាស់បុគ្គលិក និងទំនួលខុសត្រូវដែលបានឯកភាព នៅត្រឹមដំណាច់ឆ្នាំ ២០០៤ ។
- បង្កើនគណនេយ្យភាព និងការទទួលខុសត្រូវសំរាប់នាយក នាយករងសាលារៀន ក្នុងការកែលំអសាលារៀន និងការបំពេញការងាររបស់គ្រូបង្រៀន ដោយបង្កើនតួនាទីនៅក្នុងការអភិវឌ្ឍគ្រូបង្រៀន និងការវាយតំលៃការបំពេញការងាររបស់គ្រូបង្រៀន (ត្រូវបានប្រើធ្វើជាមូលដ្ឋានសំរាប់រក្សាទុកប្រាក់ឧបត្ថម្ភក្នុងការបំពេញការងាររបស់នាយក) ។ **ចំណុចដៅ** : ការកែលំអគោលការណ៍ណែនាំដែលបានឯកភាព នៅចុងឆ្នាំ ២០០៤ ។
- បង្កើនតំលាភាពនិងគណនេយ្យភាពចំពោះការសិក្សារបស់សិស្ស ការបំពេញការងាររបស់គ្រូតាមសាលារៀនក្នុងបណ្តាខេត្តនានា និងថ្នាក់ជាតិ ដោយផ្សព្វផ្សាយលទ្ធផលតែសស្តង់ដានិងលទ្ធផលប្រលងប្រចាំឆ្នាំជាសាធារណៈ និងមានរបាយការណ៍ប្រចាំឆ្នាំសំរាប់ជូនរដ្ឋសភា ។ **ចំណុចដៅ** : របាយការណ៍និងការផ្សព្វផ្សាយជាសាធារណៈចាប់ពី ចុងឆ្នាំ ២០០៤ ។
- ពង្រីកស្តង់ដាថ្នាក់ជាតិនិងការកែលំអយន្តការវាយតំលៃការទទួលស្គាល់គុណភាព ដោយប្រើប្រាស់នូវគោលវិធីបណ្តុះបណ្តាលផ្អែកលើសមត្ថភាពចំពោះកម្មវិធី TVET ។ **ចំណុចដៅ** : ផែនការសកម្មភាពត្រូវរៀបចំនៅដើមឆ្នាំ ២០០៥ ។

**ដើម្បីអនុវត្តយុទ្ធសាស្ត្របង្កើនគុណភាពនិងប្រសិទ្ធភាពនៅឧត្តមសិក្សា វិធានការនិងចំណុចដៅសំខាន់ៗរួមមានៈ**

- ចេញប្រកាសស្តីពីល័ក្ខខ័ណ្ឌនិងលក្ខណៈវិនិច្ឆ័យ ដើម្បីបញ្ជាក់អោយច្បាស់ពីការបង្កើតគ្រឹះស្ថានឧត្តមសិក្សាប្រកបដោយគុណភាពដោយផ្អែកទៅលើអនុក្រឹត្យស្តីពីការបង្កើតសាកលវិទ្យាល័យ នៅឆ្នាំ ២០០៤។
- ពង្រីកធនធាននិងពង្រឹងសមត្ថភាពជាជំហានៗ ដល់របស់គណៈកម្មការទទួលស្គាល់គុណភាពអប់រំនៅកម្ពុជាពីឆ្នាំ២០០៥តទៅ ដោយមានការសហការគ្នារវាងក្រសួងអប់រំ យុវជន និងកីឡាជាមួយនឹងទីស្តីការគណៈរដ្ឋមន្ត្រី អោយមានការរីកចំរើនជាបន្តបន្ទាប់ ដើម្បីផ្តល់ការទទួលស្គាល់គុណភាពអប់រំសំរាប់កម្មវិធីនិងគ្រឹះស្ថានឧត្តមសិក្សានានា ដូចមានចែងក្នុងព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពនៅឧត្តមសិក្សា។
- ផ្សព្វផ្សាយជារៀងរាល់ឆ្នាំអំពីល័ក្ខខ័ណ្ឌចូលរៀននៅតាមគ្រឹះស្ថានសិក្សានីមួយៗ សំរាប់គ្រប់កម្មវិធី និងអាហារូបករណ៍។ **ចំណុចដៅ** : ចាប់អនុវត្តពីដើមឆ្នាំ២០០៥ ។
- ភ្ជាប់ទំនាក់ទំនងរវាងគ្រឹះស្ថានសិក្សានិងនិយោជក ដើម្បីផ្តល់ពត៌មានអំពីទីផ្សារការងារដល់និស្សិតដោយមានការសិក្សាតាមដាន អំពីការប្រកបការងាររបស់និស្សិតក្រោយពីបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថាននីមួយៗ។ **ចំណុចដៅ** : ចាប់អនុវត្តពីដើមឆ្នាំ២០០៥។
- តំរូវអោយគ្រប់គ្រឹះស្ថានឧត្តមសិក្សាផ្សព្វផ្សាយពត៌មានជាសាធារណៈ ដូចជា ក) អត្រាប្រលងជាប់ ខ) ថ្លៃសិក្សា គ) កន្លែងបំពេញការងារនិងប្រាក់កំរៃរបស់និស្សិត ដែលបានបញ្ចប់ការសិក្សាថ្មី និង ឃ) ការត្រួតពិនិត្យគុណភាព និងការទទួលស្គាល់គុណភាពទាំងនៅក្នុងតំបន់ និងអន្តរជាតិ។
- លើកទឹកចិត្តអោយមានការចងសម្ព័ន្ធភាពរវាងគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន និងជាមួយគ្រឹះស្ថានសិក្សាក្នុងតំបន់និងអន្តរជាតិដែលល្បីឈ្មោះ ព្រមទាំងការផ្លាស់ប្តូរកម្មសិក្សា ។

(សកម្មភាពជាយុទ្ធសាស្ត្រទូទាំងវិស័យដើម្បីបង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ និងដំណាក់ការសំខាន់ៗក្នុងអំឡុងពេល ២០០៤-០៨ មានសង្ខេបជូនក្នុងឧបសម្ព័ន្ធ ២) ។

## ៣.៤. ការកសាងស្ថាប័នសំរាប់ធ្វើវិមជ្ឈការការងារអប់រំប្រកបដោយចីរភាព

នៅក្នុងដំណាក់កាលដំបូងនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០១-០៥ មានការកើនឡើងយ៉ាងខ្លាំងក្នុងការកសាងសមត្ថភាពសំរាប់ធ្វើវិមជ្ឈការការងាររបស់ផ្នែកមួយចំនួន ជាពិសេសការពង្រឹងការពិនិត្យតាមដាន និងការគ្រប់គ្រងហិរញ្ញវត្ថុនៅថ្នាក់កណ្តាល និងខេត្ត-ក្រុង ។ ពង្រឹងការកសាង ការគ្រប់គ្រង និងការពិនិត្យតាមដានផែនការកម្មវិធីទូទាំងវិស័យ។ បទពិសោធន៍សំខាន់មួយបានបង្ហាញថា ការផ្តល់សិទ្ធិអំណាច និងការ

ទទួលខុសត្រូវ គឺជាផ្នែកមួយនៃការកសាងសមត្ថភាព និងការជួយដល់កម្មវិធីបណ្តុះបណ្តាលនៅនឹងកន្លែង និងកម្មវិធីបណ្តុះបណ្តាលផ្លូវការ។ បទពិសោធន៍ផ្សេងទៀត បានបង្ហាញពីការអនុវត្តនៃការផ្តល់សិទ្ធិអំណាច ប្រកបដោយប្រសិទ្ធភាពដែលជាតំរូវការកសាងទំនុកចិត្ត និងមានចិរភាពក្នុងការគាំទ្រចរិកាដំណើរការគ្រឹះស្ថានសិក្សា។

ក្នុងដំណាក់កាលបន្ទាប់នៃកម្មវិធីកំណែទំរង់វិស័យអប់រំ គឺត្រូវពង្រឹងសមត្ថភាព និងពង្រីកការកែទំរង់ស្ថាប័ន តាមមធ្យោបាយសមស្របមួយចំនួន ។ យុទ្ធសាស្ត្រសំខាន់ដើម្បីសំរេចការងារនេះ គឺត្រូវពិនិត្យមើលការអនុវត្តវិមជ្ឈការអំពីតួនាទី និងមុខងាររបស់អគ្គនាយកដ្ឋាន និងនាយកដ្ឋាននៅថ្នាក់កណ្តាល ជាពិសេសកំណត់អោយបានច្បាស់លាស់ ពីតួនាទីក្នុងការជួយដល់ការអនុវត្ត និងការពិនិត្យតាមដាន។ យុទ្ធសាស្ត្រមួយទៀត គឺត្រូវពង្រឹងស្ថាប័ននិងកសាងសមត្ថភាពនៅថ្នាក់មូលដ្ឋាន ជាពិសេសពិនិត្យឡើងវិញពីតួនាទីនិងមុខងាររបស់ថ្នាក់ស្រុក និងសហគមន៍ក្នុងការធានាអោយមានការផ្តល់ពត៌មានដែលទាក់ទងនឹងការរីកចំរើននៃការអនុវត្តគោលនយោបាយ និងការអនុវត្តកម្មវិធីអោយបានទាន់ពេលវេលានិងមានប្រសិទ្ធភាព។ គោលបំណងសំខាន់របស់ច្បាប់អប់រំថ្មីនឹងជួយដល់ការកំនត់ទំនួលខុសត្រូវ និងសិទ្ធិអំណាចទាំងនេះ។

ភាពជាដៃគូសាធារណៈ ឯកជនដ៏រឹងមាំ និងទូលំទូលាយ មានសារៈសំខាន់ណាស់ក្នុងការកសាងសមត្ថភាព និងអភិវឌ្ឍស្ថាប័នអោយមានលក្ខណៈជាប្រព័ន្ធ។ អាទិភាពយុទ្ធសាស្ត្រទី៣ គឺត្រូវធានាភាពអាចព្យាករណ៍បាននៃកម្មវិធីផ្តល់ហិរញ្ញប្បទានពីផ្នែកសាធារណៈ ឯកជន សហគមន៍ និងធនធានពីខាងក្រៅ។ ដើម្បីធានាអោយការងារនេះដំណើរការបានល្អ ក្រសួងនឹងផ្តល់អាទិភាពដល់ការពង្រឹងអភិបាលកិច្ច កិច្ចបញ្ជិការគណនេយ្យ និងប្រព័ន្ធសវនកម្មការបំពេញការងារ អោយស្របទៅនឹងការរៀបចំផ្តល់សេវាធ្វើលទ្ធកម្មដែលមានលក្ខណៈប្រកួតប្រជែង ។

ក្រសួងអប់រំ យុវជន និងកីឡានឹងពង្រឹងទំនាក់ទំនងជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ គណៈកម្មការជាតិកែទំរង់រដ្ឋបាលសាធារណៈ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និងក្រសួងផែនការ ដើម្បីធានាថា យុទ្ធសាស្ត្រ ទាំងអស់នេះបានរៀបចំឡើងក្នុងក្របខ័ណ្ឌការងាររបស់រាជរដ្ឋាភិបាល ដើម្បីអនុវត្តវិមជ្ឈការ និងវិសហមជ្ឈការតាមយន្តការជាផ្លូវការដែលមានស្រាប់។ នៅពេលនេះដែរ ក្រសួងនឹងប្រើប្រាស់ការពិនិត្យឡើងវិញការបំពេញការងារវិស័យអប់រំប្រចាំឆ្នាំ ដើម្បីពង្រីកការចូលរួមនេះ ដោយរួមបញ្ចូលទាំងសភាជាតិ អភិបាលខេត្ត-ក្រុង ក្រុមប្រឹក្សាឃុំ-សង្កាត់ និងគណៈកម្មាការសាលារៀន មាតាបិតាសិស្ស។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ បានបញ្ចូលនូវយុទ្ធសាស្ត្ររយៈពេលមធ្យមចំនួន៤ ដើម្បីធ្វើការអភិវឌ្ឍស្ថាប័ន និងបង្កើនការកសាងសមត្ថភាពដើម្បីធ្វើវិមជ្ឈការការងារ ដូចមានខាងក្រោមនេះ :

- ពង្រឹងប្រព័ន្ធកសាងផែនការ និងពិនិត្យតាមដាននៅរដ្ឋបាលកណ្តាល និងថ្នាក់ខេត្ត-ក្រុង ។

- ❋ លើកកំពស់ប្រព័ន្ធគ្រប់គ្រងការិយាល័យអប់រំស្រុក សាលារៀន និងគ្រឹះស្ថានសិក្សា ។
- ❋ កែលំអប្រព័ន្ធលិខិតបទដ្ឋាន និងអភិបាលកិច្ច ។
- ❋ កែលំអសមត្ថភាព និងការអភិវឌ្ឍរបស់គ្រឹះស្ថានឧត្តមសិក្សា ។

**ដើម្បីអនុវត្តយុទ្ធសាស្ត្រពង្រឹងប្រព័ន្ធកសាងផែនការ និងពិនិត្យតាមដាននៅរដ្ឋបាលកណ្ដាលនិងខេត្ត -ក្រុង វិធានការ និងចំណុចដៅសំខាន់ៗរួមមាន:**

- ❑ ពង្រឹង និងពង្រីកយន្តការព្យាករណ៍ទុកជាមុនផែនការហិរញ្ញវត្ថុរយៈពេលមធ្យម និងវិមជ្ឈការនៃការគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងក្របខ័ណ្ឌនៃកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការធ្វើវិមជ្ឈការរបស់រាជរដ្ឋាភិបាល។ **ចំណុចដៅ** : ផែនការចំណាយរយៈពេលមធ្យមដែលបានឯកភាពសំរាប់វិស័យអប់រំនៅក្នុងក្របខ័ណ្ឌចំណាយសំរាប់ពេលមធ្យមឆ្នាំ២០០៤-០៨ មានបញ្ចូលការបែងចែកថវិកាសំរាប់កម្មវិធីនានា ដែលគាំទ្រដល់គោលនយោបាយអប់រំនៅត្រឹមពាក់កណ្ដាលឆ្នាំ ២០០៤។
- ❑ ធ្វើសវនកម្មផ្ទៃក្នុងអង្គភាព ដើម្បីធ្វើអោយការសំរបសំរួល និងពិនិត្យតាមដានយុទ្ធសាស្ត្រ និងកម្មវិធីកសាងសមត្ថភាពនៃប្រព័ន្ធអប់រំបានល្អប្រសើរឡើង។ **ចំណុចដៅ** : ពិនិត្យឡើងវិញពីផលប៉ះពាល់នៃការកសាងសមត្ថភាពនៅត្រឹមចុងឆ្នាំ ២០០៤ ផែនការសកម្មភាពសំរាប់អនាគតត្រូវបានរៀបចំនៅត្រឹមដើមឆ្នាំ ២០០៥។
- ❑ ពង្រឹងសមត្ថភាពមន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ និងមន្ត្រីគណនេយ្យ ហិរញ្ញវត្ថុខេត្ត-ក្រុង ស្ដីពីការកសាងផែនការយុទ្ធសាស្ត្រ និងផែនការហិរញ្ញវត្ថុ និងការពិនិត្យតាមដាននៅរដ្ឋបាលកណ្ដាល ខេត្ត-ក្រុង និងគ្រឹះស្ថានអប់រំក្រោយមធ្យមសិក្សា។ **ចំណុចដៅ** : ផែនការសកម្មភាពពេលខាងមុខត្រូវបានរៀបចំដោយរួមបញ្ចូលទាំងប្រព័ន្ធពតិមានគ្រប់គ្រងប្រតិបត្តិការហិរញ្ញវត្ថុនៅតាមខេត្ត-ក្រុង នៅត្រឹមចុងឆ្នាំ ២០០៤។
- ❑ ពង្រឹងការបំពេញការងាររបស់វិស័យអប់រំ និងការពិនិត្យតាមដានលើផលប៉ះពាល់ ព្រមទាំងការប្រមូលពតិមានផ្សេងៗបន្ថែមទៀត តាមរយៈពង្រីកការចូលរួមរបស់អ្នកពាក់ព័ន្ធទាំងឡាយ។ **ចំណុចដៅ** : ជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធនានា នៅក្នុងដំណើរការពិនិត្យឡើងវិញឯកសារកម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០០៤ និងនៅពេលក្រោយៗទៀត ព្រមទាំងកែលំអរបាយការណ៍បំពេញការងារវិស័យអប់រំ។

**ដើម្បីអនុវត្តយុទ្ធសាស្រ្ត លើកកំពស់ប្រព័ន្ធគ្រប់គ្រងការិយាល័យអប់រំស្រុក សាលារៀននិងគ្រឹះស្ថានសិក្សា វិធានការ និងចំណុចដៅសំខាន់ៗរួមមានៈ**

- ពង្រឹងប្រព័ន្ធគ្រប់គ្រងកម្មវិធីរបស់ការិយាល័យអប់រំស្រុក និងសាលារៀន តាមរយៈការកសាងសមត្ថភាពដល់អង្គភាពគ្រប់គ្រងថវិកាស្រុក កំរងសាលារៀន និងសាលារៀន ជាពិសេសដើម្បីធ្វើអោយប្រសើរឡើងការងារគ្រប់គ្រងពត៌មាន និងធ្វើរបាយការណ៍។ **ចំណុចដៅ** : កែលំអផែនការសកម្មភាព និងគោលការណ៍ណែនាំនៅត្រឹម ចុងឆ្នាំ ២០០៤។
- ពង្រីកសំភាររូបវន្តបច្ចុប្បន្ន ដើម្បីពង្រីកការប្រើប្រាស់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគអោយកាន់តែមានប្រសិទ្ធិភាព ស្របគ្នានឹងការអភិវឌ្ឍធនធានមនុស្ស ការពង្រឹងកម្មវិធីសិក្សា និងការកែលំអសំភារៈបង្រៀន និងរៀន រួមមានសំភារៈបណ្ណាល័យ កុំព្យូទ័រ និងបន្ទប់ពិសោធន៍ ។
- ពង្រឹងប្រព័ន្ធគ្រប់គ្រងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុរបស់គ្រឹះស្ថានឧត្តមសិក្សា មជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងសាលាគរុកោសល្យ ។ **ចំណុចដៅ** : រៀបចំផែនការ និងគោលការណ៍ណែនាំសំរាប់គ្រឹះស្ថានក្រោយមធ្យមសិក្សា ចាប់ពីចុងឆ្នាំ ២០០៤តទៅ។
- ពង្រឹងប្រព័ន្ធគ្រប់គ្រងបុគ្គលិកថ្នាក់ស្រុក-ខ័ណ្ឌ និងខេត្ត-ក្រុង ដោយចេញគោលការណ៍ណែនាំ និងនិយាមប្រើប្រាស់បុគ្គលិកថ្មី និងបង្កើនការផ្ទេរសិទ្ធិ ការទទួលខុសត្រូវទៅឱ្យថ្នាក់ស្រុក-ខ័ណ្ឌក្នុងការពង្រាយបុគ្គលិកអោយសមស្របទៅនឹងនិយាមកំណត់ ព្រមទាំងកសាងសមត្ថភាពដល់មន្ត្រីធ្វើផែនការថ្នាក់ខេត្ត-ស្រុក។ **ចំណុចដៅ** : ការរៀបចំគោលការណ៍ណែនាំថ្មីស្តីពីការប្រើប្រាស់បុគ្គលិក និងផែនការសកម្មភាព នឹងត្រូវបញ្ចប់រួចរាល់ នៅត្រឹមដើមឆ្នាំ២០០៥។

**ដើម្បីអនុវត្តយុទ្ធសាស្រ្តកែលំអប្រព័ន្ធលិខិតបទដ្ឋាននិងអភិបាលកិច្ច វិធានការ និងចំណុចដៅសំខាន់ៗរួមមាន :**

- ជំរុញអោយមានការអនុម័តច្បាប់អប់រំថ្មី និងរៀបចំបទបញ្ញត្តិសំខាន់ៗ ដែលទាក់ទងទៅនឹងការកែលំអស្ថាប័ន និងអភិបាលកិច្ចហិរញ្ញវត្ថុ។ **ចំណុចដៅ** : សុំការអនុម័តច្បាប់អប់រំនៅត្រឹមចុងឆ្នាំ ២០០៤ ។
- កែលំអតំលាភាពក្នុងការប្រើប្រាស់វិភាគទានរបស់មាតាបិតាសិស្ស និងផ្នែកឯកជន នៅតាមសាលារៀន និងគ្រឹះស្ថានសិក្សាដទៃទៀត តាមគោលការណ៍ណែនាំថ្មីលើការងារគណនេយ្យ និងការគ្រប់គ្រងវិភាគទានទាំងនេះ។ **ចំណុចដៅ** : ចាប់អនុវត្តគោលការណ៍ណែនាំពីដើមឆ្នាំ ២០០៥តទៅ។
- កែលំអអភិបាលកិច្ចសាលារៀន និង គ្រឹះស្ថានក្រោយមធ្យមសិក្សា ដោយចេញគោលការណ៍ណែនាំដែលកំណត់ពីអំណាច និងទំនួលខុសត្រូវរបស់ស្ថាប័នអប់រំ មាតាបិតា និងសហគមន៍។ **ចំណុចដៅ** : ចេញគោលការណ៍ណែនាំ នៅដើមឆ្នាំ ២០០៥។

**ដើម្បីអនុវត្តយុទ្ធសាស្ត្រកែលំអសមត្ថភាពនិងការអភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សាវិធានការនិងចំណុចដៅសំខាន់ៗ រួមមាន :**

- ចេញប្រកាសក្នុងឆ្នាំ២០០៤ ដើម្បីសំរបសំរួលតួនាទីរបស់គ្រឹះស្ថានរដ្ឋបាលសាធារណៈនៅឆ្នាំ២០០៥ សំរាប់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈទាំងអស់ រួមទាំងការបង្កើតក្រុមប្រឹក្សាភិបាល ការតែងតាំងគណនេយ្យករសាធារណៈ និងសវនករ ។
- បង្កើតកម្មវិធីលើកទឹកចិត្តមន្ត្រីអប់រំ មន្ត្រីជំនាញ អ្នកឯកទេស និងអ្នកគ្រប់គ្រងថ្នាក់ខ្ពស់ ដើម្បីកែលំអធនធានមនុស្សនៅក្នុងប្រព័ន្ធអប់រំ និងនៅគ្រឹះស្ថានឧត្តមសិក្សា ។
- ចេញប្រកាសស្តីពីល័ក្ខខ័ណ្ឌនៃគុណវុឌ្ឍិ (Qualification) បទពិសោធន៍ លទ្ធភាព និងលទ្ធផលបំពេញការងារដែលរំពឹងទុករបស់មន្ត្រីឧត្តមសិក្សារួមមានមន្ត្រីអប់រំ មន្ត្រីជំនាញ អ្នកឯកទេស អ្នកគ្រប់គ្រងជាន់ខ្ពស់ នាយក ព្រឹទ្ធបុរស សាកលវិទ្យាធិការ និងប្រធានគ្រឹះស្ថានឧត្តមសិក្សា ។ **ចំណុចដៅ:** ដាក់ចេញ នៅឆ្នាំ ២០០៥ ។
- ពង្រឹងសមត្ថភាពរបស់នាយកដ្ឋានឧត្តមសិក្សា ដើម្បីពិនិត្យតាមដាន វិភាគ និងរៀបចំគោលនយោបាយ ដើម្បីបង្កើនការចូលរៀនអោយមានសមធមិ មានគុណភាព និងការគ្រប់គ្រងគ្រឹះស្ថានសិក្សា ដោយបង្កើតប្រព័ន្ធគ្រប់គ្រងពតិមានឧត្តមសិក្សា ។ **ចំណុចដៅ :** អនុវត្តនៅឆ្នាំ ២០០៥ ។
- បង្កើនធនធាននៅនាយកដ្ឋានឧត្តមសិក្សា ដោយមានរៀបចំការគ្រប់គ្រងទិន្នន័យតាមកុំព្យូទ័រ និងបណ្តាញពតិមាន ដើម្បីភ្ជាប់នាយកដ្ឋានឧត្តមសិក្សា ជាមួយនឹងគណៈកម្មការទទួលស្គាល់គុណភាពអប់រំនៅកម្ពុជានិងគ្រឹះស្ថានឧត្តមសិក្សានានា ដើម្បីធ្វើអោយការពង្រីកពតិមានកាន់តែមានប្រសិទ្ធភាពជាមួយនិយោជក ក្រសួងពាក់ព័ន្ធនានា និងទីផ្សារពលកម្មដទៃទៀត ។ **ចំណុចដៅ :** អនុវត្តនៅឆ្នាំ ២០០៥ ។
- បង្កើនធនធានរបស់នាយកដ្ឋានឧត្តមសិក្សា រួមមានសំភារៈការិយាល័យ មន្ត្រីជំនាញ និងថវិកាដំណើរការ ដើម្បីជួយពង្រឹងដល់ការផ្លាស់ប្តូរតួនាទី និងសមត្ថភាពរបស់នាយកដ្ឋាន ។
- បង្កើនធនធាននានាដល់គណៈកម្មាការទទួលស្គាល់គុណភាពអប់រំនៅកម្ពុជា រួមមានទីកន្លែង សំភារៈការិយាល័យ មន្ត្រីជំនាញ និងថវិកាដំណើរការ ដើម្បីពង្រឹងអភិបាលកិច្ច និងសមត្ថភាពវិជ្ជាជីវៈ ។
- លើកកំពស់គុណភាពកម្មវិធីសិក្សា ការផ្តល់សេវាអប់រំគ្រប់រូបភាព និងធនធានសំរាប់បង្រៀន និងរៀន រួមមានបណ្ណាល័យ សំភារបរិក្ខារកុំព្យូទ័រ និងទីពិសោធន៍នៅគ្រប់គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ។
- បន្តកសាងគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្ស និងល័ក្ខខ័ណ្ឌការងារសំរាប់មន្ត្រីនៅគ្រប់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ នៅនាយកដ្ឋានឧត្តមសិក្សា និងគណៈកម្មាការទទួលស្គាល់គុណភាពអប់រំ

នៅកម្ពុជា ដើម្បីគាំទ្រដល់ការគ្រប់គ្រងប្រកបដោយតំលាភាព ការទទួលខុសត្រូវ និងកាត់បន្ថយភាព មិនប្រក្រតី នៅក្នុងប្រព័ន្ធឧត្តមសិក្សា ។

(សកម្មភាពជាយុទ្ធសាស្ត្រទូទាំងវិស័យសំរាប់កែលំអការកសាងសមត្ថភាព ដើម្បីធ្វើវិមជ្ឈការការងារ និង ដំណាក់កាលសំខាន់ៗក្នុងអំឡុងពេល ២០០៤-០៨ មានសង្ខេបជូនក្នុងឧបសម្ព័ន្ធ ៣) ។